# សេវាកម្មចាត់បញ្ជូនគ្រួសារមាន កូនតូចឲ្យទទួលបានជំនួយ

## កម្មវិធីអាហារូបត្ថម្ភ WIC (WIC Nutrition Program)

ឬហៅទូរស័ព្ទមកលេខ 207-287-3991

WIC បម្រើសេវាដល់ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន និងកុមារអាយុរហូតដល់ 5 ឆ្នាំ ដោយបូករួមទាំងក្មេងដែលគេទទួលចិញ្ចឹមផងដែរ ។ WIC គឺជាអ្នកផ្តល់អាហារូបត្ថម្ភដ៏ពេញលេញ និងផ្តល់ជូនអាហារសុខភាព ការអប់រំអំពីអាហារូបត្ថម្ភ ជំនួយគាំទ្រផ្នែកបំបៅកូនដោយទឹកដោះ ម្តាយ និងការចាត់បញ្ជូនឲ្យទទួលបានសេវាកម្មផ្សេងទៀត ។

## សេវាកម្មអភិវឌ្ឍន៍កុមារ/ អន្តរាគមន៍កុមារតូច (Child Development Services/ Early Intervention)

ឬហៅទូរស័ព្ទមកលេខ 877-770-8883

ប្រព័ន្ធសេវាកម្មអភិវឌ្ឍន៍កុមារ/អន្តរាគមន៍កុមារតូច ជាក្រុមអប់រំអន្តរការី ដែលផ្តល់សេវាកម្មអន្តរាគមន៍កុមារតូច (ពីពេលកើត រហូតអាយុពីរឆ្នាំ) និងជំនួយសេវាកម្មអប់រំសាធារណៈដែលមានភាពសមរម្យ ដោយមិនគិតប្រាក់ (សម្រាប់កុមារអាយុបីដល់ប្រាំឆ្នាំ) ក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានអប់រំប្រចាំរដ្ឋមេន ។

## កុមារមានតម្រូវការពិសេសផ្នែកការ ថែទាំសុខភាព (CSHN, Child with Special Health Care Needs)

ឬហៅទូរស័ព្ទមកលេខ 800-698-3624

អង្គការកុមារមានតម្រូវការពិសេសផ្នែកការថែទាំសុខភាព ធ្វើការជាមួយគ្រួសារដែលមានកូនមានតម្រូវការពិសេសផ្នែកការថែទាំសុខភាព ដែលមានអាយុក្រោម 22 ឆ្នាំ ។ អង្គការ CSHN អាចជួយណែនាំផ្លូវដល់គ្រួសារទាំងនោះ និងអង្គការនានា ក្នុងការស្វែងរកធនធានដែលអាចផ្តល់ជំនួយបានប្រសើរបំផុតចំពោះតម្រូវការរបស់កូនៗទាំងអស់ ។ បុគ្គលិករបស់អង្គការ អាចណែនាំដល់គ្រួសារទាំងនោះ តាមរយៈប្រព័ន្ធវេជ្ជសាស្ត្រ ដែលមានភាពស្មុគស្មាញ ភ្ជាប់ទំនាក់ទំនងរបស់ពួកគេទៅកាន់សេវាកម្មថែទាំសុខភាព ដែលអាចធ្វើឲ្យការថែទាំព្យាបាល បានផលប្រសើរបំផុតចំពោះអ្នកជំងឺ ។

## ផែនការថែទាំដោយសុវត្ថិភាព (POSC, Plan of Safe Care)

ផែនការរបស់រដ្ឋមេន អំពីការថែទាំប្រកបដោយសុវត្ថិភាព ត្រូវបានបង្កើតឡើងរវាងអ្នកផ្តល់សេវាកម្មការថែទាំសុខភាព ឬអ្នកផ្តល់សេវាកម្មសង្គមកិច្ច, ម្តាយ និង/ឬអ្នកមើលថែក្មេងផ្សេងទៀត ដើម្បីកំណត់រកភាពខ្លាំង និងតម្រូវការរបស់គ្រួសារ ធនធានដែលមានប្រយោជន៍ និងសកម្មភាព ដើម្បីអាចផ្តល់ភាពជ្រោមជ្រែងបានប្រសើរបំផុតដល់ទារក និងគ្រួសាររបស់ពួកគេដែលកំពុងប្រឈមនឹងសារធាតុញៀន ។ ផែនការការថែទាំប្រកបដោយសុវត្ថិភាព ជាធម្មតា មានរួមបញ្ចូលនូវសេវាកម្មចាត់បញ្ជូនទៅសេវាកម្មនានា ឬផ្តល់ជូនព័ត៌មានទំនាក់ទំនង ដល់គ្រួសារ ដើម្បីយកទៅប្រើប្រាស់នៅពេលក្រោយ ។

## កម្មវិធីធានារ៉ាប់រងសុខភាពរដ្ឋមេន (Health Coverage for Maine)

ឬហៅទូរស័ព្ទមកលេខ 1-855-797-4357

កម្មវិធីធានារ៉ាប់រងសុខភាពរដ្ឋមេន (Health Coverage for Maine) (CoverME.gov) មានផ្តល់ជូនព័ត៌មានអំពីការធានារ៉ាប់រងសុខភាព ដោយឥតគិតថ្លៃ និងតម្លៃថោក ដែលជាជម្រើសសម្រាប់គ្រួសាររដ្ឋមេន ។ អ្នកក៏អាចស្វែងរកកម្រងព័ត៌មានអំពីអង្គការប្រចាំមូលដ្ឋាន ដែលអាចជួយអ្នកឲ្យយល់បាននូវជម្រើសការធានារ៉ាប់រងសុខភាពរបស់អ្នក និងការបំពេញពាក្យសុំទិញធានារ៉ាប់រងសុខភាព ។

## ប្រព័ន្ធចាត់បញ្ជូន CradleME (Cradle ME Referral System)

ឬហៅទូរស័ព្ទមកលេខ 1-888-644-1130

CradleME ជួយភ្ជាប់ទំនាក់ទំនងរវាងអ្នក ជាមួយនឹងសេវាកម្មនៅតាមផ្ទះដែលត្រឹមត្រូវ សម្រាប់អ្នក និងកូនអ្នកដោយឥតគិតថ្លៃ ។ CradleME គឺជាគម្រោងក្នុងភាពជាដៃគូ រវាងកម្មវិធីចំនួនពីរ ៖ ការថែទាំសុខភាពសាធារណៈ និងគ្រួសាររដ្ឋមេន ។

## គ្រួសាររដ្ឋមេន (Maine Families)

គ្រួសាររដ្ឋមេន (Maine Families) គឺជាបណ្តាញទូទាំងរដ្ឋ នៃក្រុមសហគមន៍ដែលបម្រើសេវាកម្មចំពោះស្ត្រីមានផ្ទៃពោះ និងឪពុកម្តាយដែលមានទារកទើបកើត ។ ក្រុមអ្នកមើលថែ និងអ្នកចុះជួយតាមផ្ទះដែលមានវិជ្ជាជីវៈ នឹងចាប់ដៃគូជាមួយនឹងអ្នក ដើម្បីអាចទទួលបានព័ត៌មាន និងធនធាននានា ដែលអាចជួយជ្រោមជ្រែងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តនៃកូនតូចរបស់អ្នក និងគ្រួសារអ្នកទាំងមូល ។

## ការថែទាំសុខភាពសាធារណៈ (PHN, Public Health Nursing)

ឬហៅទូរស័ព្ទមកលេខ 1-888-644-1130

ផ្នែកថាំទាំសុខភាពសាធារណៈប្រចាំមជ្ឈមណ្ឌលគ្រប់គ្រងជំងឺរដ្ឋមេន មានបម្រើសេវាកម្មថែទាំសុខភាពតាមផ្ទះដល់គ្រួសាររបស់រដ្ឋមេន ។ គិលានុបដ្ឋាកសុខភាពសាធារណៈ អាចចុះជួយស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលទើបសម្រាលកូនរួច និងទារកទើបកើត ព្រមទាំងទារកដែលមានអាយុរហូតដល់ 12 ខែ ។ បើអ្នកមានសំណួរអំពីសុខភាពរបស់អ្នក ឬអំពីសុខភាពទារករបស់អ្នក អ្នកអាចស្នើសុំជួបគិលានុបដ្ឋាកបានគ្រប់ពេល ដោយការហៅទូរស័ព្ទមកកាន់លេខរបស់ ក្រុម CradleME ។

**ដើម្បីស្កេនលេខកូដ QR សូមបើកកាមេរ៉ាក្នុងឧបករណ៍របស់អ្នក ។ ផ្តង់ចាប់រូបសញ្ញា លេខកូដ QR ដែលអ្នកចង់ស្កេន ។ ចូររកមើលបដាផ្តល់ដំណឹងដែលនៅផ្នែកខាងលើនៃអេក្រង់ រួចចុចលើវា ដើម្បីចូលទៅកាន់វិបសៃត៍ នោះ ។**

**អង្គភាពនេះផ្តល់ឱកាសស្មើភាពដល់មនុស្សគ្រប់រូប ។**